# រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា

# ប្រព័ន្ធគ្រប់គ្រងព័ត៌មាន



អង្គការពលកម្មអន្តរជាតិ



# រោងចក្រកាន់តែប្រសើរនៅកម្ពុជា

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាគំរោងពិសេសមួយរបស់អង្គការពលកម្មអន្តរជាតិ ដែលបាននិងកំពុងរាយការណ៍ពីល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រកាត់ដេររបស់ប្រទេសកម្ពុជា ដោយប្រៀបធៀបជាមួយនឹងបទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិ ចាប់តាំងពីឆ្នាំ ២០០១ មកម្ល៉េះ។ គំរោងនេះ ជួយរោងចក្រឱ្យកែលំអល័ក្ខខ័ណ្ឌការងារ អនុលោមទៅតាមបទដ្ឋានការងារ និងបង្កើនផលិតភាព តាមរយៈការត្រួតពិនិត្យការធ្វើឱ្យប្រសើរឡើងក្នុងកិរិតរោងចក្រកាត់ដេរ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ។ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ធ្វើការជាមួយរាជរដ្ឋាភិបាល អ្នកគ្រប់គ្រងរោងចក្រ អង្គភាពរបស់និយោជក សហជីព និងអ្នកបញ្ជាទិញអន្តរជាតិ ដើម្បីធ្វើអោយប្រាកដថាការត្រួតពិនិត្យ ការរាយការណ៍ និងប្រព័ន្ធកែលំអ មាននិរន្តរភាពក្នុងរយៈពេលវែង ។

## ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មី (IMS)

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMS) លើកដំបូងបង្អស់មួយលើពិភពលោក ដើម្បីធ្វើការត្រួតពិនិត្យ និងរាយការណ៍ពីល័ក្ខខ័ណ្ឌការងារ។ IMS គឺជាប្រព័ន្ធដើរដោយកុំព្យូទ័រទាំងស្រុង សំរាប់ប្រមូល រក្សាទុក និងវិភាគទិន្នន័យ។ ប្រព័ន្ធព័ត៌មាននេះ អនុញ្ញាតឱ្យមានការបង្កើតរបាយការណ៍ដែលត្រូវបានសិរិតសំរាំងឱ្យសមស្របទៅតាមតំរូវការរបស់អ្នកប្រើប្រាស់ និងផ្តល់នូវការធានាសន្តិសុខល្អប្រសើរ ការងាយស្រួលចូលមើលព័ត៌មាន និងតម្លាភាពប្រសើរជាងមុន។

IMS ធ្វើឱ្យមានប្រសិទ្ធិភាព និងរួមបញ្ចូលគ្នានូវទិន្នន័យដែលប្រមូលបាន ក្នុងកំឡុងពេលចុះត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារតាមរោងចក្រ ។ ដោយធ្វើការចងក្រងព័ត៌មាននេះតាមប្រព័ន្ធអេឡិចត្រូនិក *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ឥឡូវនេះបង្កើតរបាយការណ៍ដោយស្វ័យប្រវត្តិសំរាប់រោងចក្រនីមួយៗ ដែលបង្ហាញពីការអនុវត្តន៍តាមច្បាប់នាពេលបច្ចុប្បន្នរបស់រោងចក្រទាំងនោះ វឌ្ឍនភាពសំរេចបានក្នុងរយៈពេលមួយ ក៏ដូចជាសំណូមពរនានាសំរាប់ការកែលំអ ។ ប៉ុន្តែ IMS អាចធ្វើការបានលើសពីនេះទៅទៀត។ ដោយសារតែប្រព័ន្ធទិន្នន័យអេឡិចត្រូនិករបស់វា IMS ក៏អាចផ្តល់ជូននូវរបាយការណ៍អំពីរោងចក្រជាក្រុម១ ឬអំពីឧស្សាហកម្មទាំងមូលផងដែរ ។ ប្រព័ន្ធនេះ អាចប្រៀបធៀបការប្រតិបត្តិរបស់រោងចក្រប្រភេទផ្សេងគ្នា រៀបលំដាប់ថ្នាក់បញ្ហាសំខាន់១ និងព័ត៌មានបញ្ចូលគ្នាលំអិតផ្សេង១ ដែលចាំបាច់សំរាប់ការវិភាគ ។ IMS ក៏រក្សាទុកផងដែរនូវទិន្នន័យស្តីពីកម្មវិធីបណ្តុះបណ្តាលរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ហើយអាចតាមដានការចូលរួមរបស់រោងចក្រ ក៏ដូចជាលទ្ធផលរបស់កម្មវិធីទាំងនេះ ។

IMS បង្កលក្ខណះឱ្យ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* អាចបង្កើតរបាយការណ៍បានជាភាសាខ្មែរ អង់គ្លេស និងចិន ។ របាយការណ៍ទាំងនេះកាន់តែមានភាពងាយស្រួលសំរាប់អ្នកប្រើប្រាស់ ។ ដោយសារតែប្រព័ន្ធនេះមានមូលដ្ឋានលើអ៊ីនធឺណិត ការចូលមើលព័ត៌មាន មានភាពឆាប់រហ័ស និងងាយស្រួល ។

# តើរោងចក្រកាន់តែប្រសើរនៅកម្ពុជាត្រួតពិនិត្យអ្វីខ្លះ?

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ត្រួតពិនិត្យដោយធ្វើការប្រៀបធៀបជាមួយនឹងច្បាប់ការងារកម្ពុជា ដែលក្នុងនោះរួមទាំងការប្តេជ្ញាចិត្តដើម្បីបំពេញបទដ្ឋានការងារអន្តរជាតិសំខាន់ៗ។ គំរោងនេះត្រួតពិនិត្យជាង ៥០០ បញ្ហាផ្សេងៗគ្នាពីបញ្ជីត្រួតពិនិត្យ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ក៏ដូចជានិយោជក និងសហជីព ដែលពាក់ព័ន្ធក្នុងឧស្សាហកម្មកាត់ដេរ។ ការត្រួតពិនិត្យបទដ្ឋានការងារអន្តរជាតិសំខាន់ៗរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គ្របដណ្តប់លើការងារដោយបង្ខំ ពលកម្មកុមារ សេរីភាពនៃការចូលរួមសហជីព សិទ្ធិទទួលបានអនុសញ្ញារួម និងការរើសអើង ។ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក៏ត្រួតពិនិត្យផងដែរ លើតម្រូវការច្បាប់របស់កម្ពុជាចំពោះប្រាក់ឈ្នួល ថិរវេលាធ្វើការ កិច្ចសន្យាការងារ ការឈប់សំរាក សុវត្ថិភាពនិងសុខភាពការងារ សុខមាលភាព និងទំនាក់ទំនងវិជ្ជាជីវៈ ។



## រោងចក្រទទួលបានអត្ថប្រយោជន៍ព្រោះ IMS

● បង្កើតរបាយការណ៍ត្រួតពិនិត្យ ដែលងាយស្រួលយល់ និងលំអិត ● បង្កើនល្បឿន គុណភាព និងភាពស្របគ្នានៃការរាយការណ៍ ● បង្កើតរបាយការណ៍ជាភាសាខ្មែរ អង់គ្លេស និងចិន ● កាត់បន្ថយភាពចាំបាច់សំរាប់សវនកម្មរោងចក្រច្រើនលើកច្រើនសារ ដោយអ្នកបញ្ជាទិញផ្សេងគ្នា ● អនុញ្ញាតឱ្យរោងចក្រគ្រប់គ្រងការអនុវត្តន៏ច្បាប់យ៉ាងសកម្ម តាមរយៈការប្រើប្រាស់ឧបករណ៏របស់ IMS ដើម្បីវាយតំលៃខ្លួនឯង ● វាស់វែងវឌ្ឍនភាពរបស់រោងចក្រ លើការអនុវត្តន៏តាមច្បាប់ការងារ ដោយប្រៀបធៀបជាមួយនឹងកំរិតមធ្យមនៃឧស្សាហកម្ម ● ជួយអ្នកបណ្តុះបណ្តាល រៀបចំកម្មវិធីជាក់លាក់ ដើម្បីដោះស្រាយបញ្ហានៃការអនុវត្តន៏ច្បាប់ដែលកើតម្តងហើយម្តងទៀត



## អ្នកបញ្ជាទិញ និងអ្នកលក់ ទទួលបានអត្ថប្រយោជន៍ព្រោះ IMS

● ផ្តល់របាយការណ៏ដែលងាយស្រួលអាន និងមានគុណភាពប្រសើរជាងមុន ● ផ្តល់លទ្ធភាពងាយស្រួលចូលមើលរបាយការណ៏រោងចក្រតាមប្រព័ន្ធអ៊ីនធឺណិត ● អនុញ្ញាតឱ្យរោងចក្រ ធ្វើការសំរេចចិត្តឱ្យអ្នកដែលនឹងអាចចូលមើលរបាយការណ៏របស់គេបាន ● បង្កើតរបាយការណ៏ដែលមានការសំរិតសំរាំង ដោយធ្វើការប្រៀបធៀបកំរិតអនុវត្តន៏ច្បាប់របស់រោងចក្រដែលបានជ្រើសរើស ● កាត់បន្ថយការត្រួតពិនិត្យជាន់គ្នា និងកាត់បន្ថយថ្លៃចំណាយ ● ជំរុញឱ្យមានការសំរបសំរួលកាន់តែប្រសើរជាងមុន រវាងអ្នកបញ្ជាទិញ និងអ្នកលក់ ● អនុញ្ញាតឱ្យមានការកែលំអ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដែលកាន់តែមានប្រសិទ្ធិភាពជាងមុន



## អង្គភាពរបស់និយោជក សហជីព និង សាធារណជន ទទួលបានអត្ថប្រយោជន៍ព្រោះ IMS

● រួមចំណែកក្នុងការធានានិរន្តរភាពរបស់ឧស្សាហកម្មកាត់ដេរ ● ផ្តល់នូវការចូលមើលព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ទាន់ពេលវេលា និងងាយស្រួលសំរាប់អ្នកប្រើប្រាស់ ● បង្កើនតម្លាភាពនៃការត្រួតពិនិត្យ និងការរាយការណ៏ ● បង្កើតទិន្នន័យវិភាគ ដែលអាចយកមកប្រើប្រាស់ ដើម្បីកែលំអគោលនយោបាយ និងការអភិវឌ្ឍន៏កម្មវិធី ● បំពេញតំរូវការព័ត៌មានរបស់ពួកគេ ● គឺជាមធ្យោបាយដ៏មានអានុភាព សំរាប់ការវិភាគលើបញ្ហាជាក់លាក់

# តើប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMS) ដំណើរការយ៉ាងដូចម្តេច?

ខណៈពេលដែលអ្នកឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិ នៅតែចុះពិនិត្យរោងចក្រដូចមុនដដែល ឥឡូវនេះពួកគេកត់ត្រាលទ្ធផលដោយផ្ទាល់លើកុំព្យូទ័រតូចៗ ដែលត្រូវបានបង្កើតឡើងជាពិសេសដើម្បីប្រមូលទិន្នន័យ ។ បន្ទាប់ពីការចុះត្រួតពិនិត្យរោងចក្រនីមួយៗ អ្នកឃ្លាំមើលពិនិត្យឡើងវិញ និងកែតំរូវព័ត៌មានដែលបានប្រមូល ។

បន្ទាប់មកប្រធានទីប្រឹក្សាបច្ចេកទេស ដែលជាអ្នកដឹកនាំគំរោងនេះ ផ្តល់ការសំរេចអនុម័តចុងក្រោយ ។ នៅពេលដែលរបាយការណ៍រោងចក្រត្រូវបានអនុម័ត និងបញ្ជូនចូលទៅក្នុង IMS គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នឹងជូនដំណឹងដល់រោងចក្រតាមរយៈអ៊ីម៉ែល ។ រោងចក្រអាចចូលទៅក្នុងវិបសាយ ដែលផ្តល់ការប្រើប្រាស់មានកំរិត (extranet) របស់ IMS ដោយប្រើពាក្យសំងាត់ ដើម្បីបើកមើលរបាយការណ៍លំអិតរបស់ពួកគេ ។ អ្នកប្រើប្រាស់ដទៃទៀត (ដូចជា ការិយាល័យកណ្តាល អ្នកបញ្ជាទិញ ឬអ្នកលក់) ក៏អាចចូលមើលរបាយការណ៍របស់រោងចក្រជាក់លាក់ណាមួយបានផងដែរ ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឱ្យចូលមើល ។ ចំពោះរោងចក្រដែលពុំមានអ៊ីម៉ែល ឬអ៊ីនធឺណិត ទទួលរបាយការណ៍របស់ពួកគេជាឯកសារបោះពុម្ព ។

IMS បន្តការបង្ហាញឈ្មោះរោងចក្រ និងរាយការណ៍ពីវឌ្ឍនភាពរបស់រោងចក្រក្នុងការអនុវត្តន៏តាមសំណូមពរកែលំអ ដែលផ្តល់ដោយអ្នកឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិ ។ សាធារណជនអាចចូលមើលព័ត៌មានសង្ខេបនេះបានតាមរយៈវិបសាយរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។ របាយការណ៍សង្ខេបទាំងនេះ នឹងត្រូវផ្សាយអោយដឹង បន្ទាប់ពីរបាយការណ៍រោងចក្រត្រូវបានបញ្ចប់ ។

IMS ក៏អនុញ្ញាតឱ្យមានការវិភាគលើការអនុវត្តន៏ច្បាប់កាន់តែប្រសើរផងដែរ ។ ឥឡូវនេះ របាយការណ៍សំយោគថ្មីមានដាក់បញ្ចូលក្រាហ្វិកងាយស្រួលអាន ដែលបង្ហាញពីទិន្នាការនៃការអនុវត្តន៏ច្បាប់ តួលេខការងារសំរាប់ឧស្សាហកម្មកាត់ដេរ និងវឌ្ឍនភាពនៃការកែលំអលក្ខខ័ណ្ឌការងារ ។ ក្រាហ្វិកទាំងនេះត្រូវបានចេញផ្សាយជារៀងរាល់បីខែម្តង ជាភាសាខ្មែរ អង់គ្លេស និងចិន ដែលជាភាសានិយាយភាគច្រើនដោយអ្នកប្រើប្រាស់ ។ ទន្ទឹមពេលដែលប្រព័ន្ធព័ត៌មាននេះវិវឌ្ឍទៅមុខ សមត្ថភាពរាយការណ៍ក៏វិវឌ្ឍដូច្នោះដែរ ។ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* រំពឹងថា នាពេលអនាគតអ្នកប្រើប្រាស់នឹងអាចបង្កើតរបាយការណ៍ដើម្បីបំពេញតំរូវការផ្ទាល់ខ្លួនរបស់ពួកគេ ។

*សំរាប់ព័ត៌មានបន្ថែមសូមមើលវិបសាយរបស់យើង: www.betterfactories.org/ilo*




ប្រភព: ឧទាហរណ៍ប្រឌិត




*សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:*

**រោងចក្រកាន់តែប្រសើរនៅកម្ពុជា**
**អង្គការពលកម្មអន្តរជាតិ**
ផ្ទះលេខ៩ ផ្លូវ៣២២
សង្កាត់បឹងកេងកង ១
ខ័ណ្ឌចំការមន ភ្នំពេញ
កម្ពុជា

ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ: (៨៥៥-២៣) ២១២-៨៤៧ ឬ ២២០-៣៦២
លេខបន្ត ១០៦-១០៧
ទូរសារ: (៨៥៥-២៣) ២១២-៩០៣
អ៊ីម៉ែល: betterfactories@ilo.org
វិបសាយ: www.betterfactories.org/ilo